# <u>សេចក្តីជូនដំនឹង</u>

PUBLIC ANNOUNCEMENT

# ដើមបណ្តឹងរដ្ឋប្បវេណី សំរាប់ "ក្រុមអ្នកកំព្រា"

**CIVIL PARTY of 'ORPHANS CLASS'**

**ប្រធានបទ:** សិក្ខាសាលា ស្តីអំពី ការដាក់ពាក្យធ្វើជា **ដើមបណ្តឹងរដ្ឋប្បវេណី** សំរាប់ **"ក្រុមអ្នកកំព្រា"** គឺជាជនជាតិកម្ពុជា ដែលបានបាត់បង់ ឪពុក និង ម្តាយ ក្នុងចន្លោះពី ខែមេសា ឆ្នាំ ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩។

**ពេលវេលា:** ថ្ងៃសៅរ៍ ទី ១៩, ខែមេសា, ឆ្នាំ២០០៨, ពីម៉ោង ៨ ព្រឹក ដល់ ៤ រសៀល

**ទីកន្លែង:** មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ហៅកាត់ថា **"CSD"** ។ ផ្ទះលេខ ១៩, ផ្លូវ ៥៧ (ចន្លោះ ផ្លូវប៉ាស្ទ័រ ៥១ និង ផ្លូវ ត្រសក់ផ្អែម ៦៣), សង្កាត់ បឹងកេងកង១, ខណ្ឌចំការមន, ភ្នំពេញ ។

**វាគ្មិន:** កញ្ញា សេង ធារី, ជា ដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងស្វះស្វែង ដើម្បីធ្វើជាអ្នក តំណាងអោយក្រុមអ្នកកំព្រា ក្នុងករណីព្រហ្មទណ្ឌ ទាក់ទងទៅនឹង មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ (រួមមាន លោក នួន ជា, លោក ខៀវ សំផន, លោក អៀង សារី, និង អ្នកស្រី អៀង ធារិទ្ធ) ។ ធារី នឹងពន្យល់ ពីដំណើរការ និង ជួយក្នុងការបំពេញ សំណុំបែបបទ សំរាប់អ្នកដែលមានចំណាប់អារម្មណ៍ ។

**សូមទំនាក់ទំនង:** theary@csdcambodia.org ឬ តាមទូរស័ព្ទ លេខ៖ ០២៣.៣៦៤.៧៣៥ ឬ ស៊ីវនិន្ទ ០១៧.៩៩៣.១១៨ ។

**អ្នកចូលរួម:** ជនជាតិកម្ពុជា ដែល ឪពុក <u>និង</u> ម្តាយ បានបាត់ខ្លួន ឬ បានស្លាប់ ឬ ត្រូវបានគេសំលាប់ នៅក្នុងអំឡុងពេលរបបខ្មែរក្រហម (ពី ខែមេសា ឆ្នាំ ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩) ។ CSD សូមស្វាគមន៍ អ្នកចូលរួម ដែលអាចជាជនជាតិកម្ពុជា ដែលកំពុងរស់នៅ បរទេស, មកពីជនបទ ឬ កំពុងរស់នៅក្នុងទីក្រុងភ្នំពេញ ។ CSD ត្រៀមរៀបចំទទួល អ្នកចូលរួមពី ៥០ ទៅ ៧៥ នាក់ សំរាប់សិក្ខាសាលានេះ ។

**កំណត់ចំណាំ:** សូមបញ្ជាក់ថា ការចូលរួមក្នុងសិក្ខាសាលា និង ការទទួលបាននូវសំណុំបែបបទពាក្យបណ្តឹងនេះ មិនតំរូវអោយបង់ថ្លៃឡើយ ។ CSD នឹងផ្តល់ជូន នូវអាហារថ្ងៃត្រង់, ភេសជ្ជៈ, និង អាហារសំរ៉ន់ សំរាប់ អ្នកចូលរួម ។ អ្នកចូលរួម ត្រូវទទួលខុសត្រូវ ក្នុងការ ធ្វើដំណើរមក CSD និង ត្រឡប់ទៅវិញ ដោយខ្លួនឯង (សំរាប់ អ្នកដែលមិនរស់នៅក្នុងទី ក្រុងភ្នំពេញ និង មកពីតាមបណ្តាខេត្តនានា ក្នុងប្រទេសកម្ពុជា, CSD នឹង ផ្តល់ជូន នូវថវិកា ចំនួន ១០ដុល្លា ។ ការផ្តល់ជូននេះ សំរាប់តែអ្នកចុះឈ្មោះ ៧៥ នាក់ដំបូង តែប៉ុណ្ណោះ)។ CSD នឹងអញ្ជើញ មេធាវីជាតិ និង អន្តរជាតិ ដែលចាប់អារម្មណ៍ក្នុងការតំណាង

"ក្រុមអ្នកកំព្រា", ព្រមទាំងបុគ្គលិកនៅក្នុង អង្គភាពជនរងគ្រោះ នៃ អង្គជំនុំជម្រះវិសាមញ្ញ នៅក្នុង តុលាការកម្ពុជា មកចូលរួម និង ជួយក្នុងការបំពេញ សំណុំបែបបទពាក្យបណ្ដឹង ផងដែរ ។ បុគ្គលិក CSD និង និស្សិតស្ម័គ្រចិត្ត មកពីសាកលវិទ្យាល័យនានា នឹងជួយអ្នកចូលរួម ក្នុងការបំពេញសំណុំ បែបបទនេះ ក្នុងករណីចាំបាច់ ។ CSD នឹងរក្សាការសំងាត់នូវរាល់ សំនួរ និង សំណូមពរ ដែលអ្នកចូលរួម បានលើកឡើង ។

**WHAT:** Civil Party application seminar for the "Orphans Class".

**WHEN:** Saturday, 19 April 2008. 8 a.m.–4 p.m.

**WHERE:** The Center for Social Development (**"CSD"**). No. 19, Street 57, Bung Keng Kang I (between Streets 51 Pasteur and 63 Trasak Paem), Phnom Penh.

**WHO:** *Theary C. SENG*: civil party who seeks to represent the "Orphans Class" against the senior KR leaders (Nuon Chea, Khieu Samphan, Ieng Sary, Ieng Thirith). Theary will explain the process and assist in completing the forms for interested individuals. Contact: theary@csdcambodia.org or CSD, 023.364.735, or Sivnin at 017.993.118.

**FOR WHOM:** Cambodians who have **both** father and mother disappeared, killed, died during the Khmer Rouge years (between April 1975–January 1979). You can be Cambodians living overseas, from the countryside or living here in Phnom Penh. All are welcomed. We will make arrangement to receive 50-75 applicants at this seminar.

**NOTE:** Please note that the seminar with application forms is free. CSD will provide lunch, drinks and snacks for participants. The participants are responsible for getting to and from CSD (except that we will provide US$10 reimbursement to each of participants living within Cambodia but outside Phnom Penh, for up to the first 75 people, on an actual need basis.) CSD will also invite Khmer and international lawyers who are interested in representing this "Orphans Class" and staff of the ECCC Victims Unit to attend and assist with filling out these applications. CSD staff and university student volunteers will also be on hand to assist the participants in completing the form, should assistance be required. **We will preserve confidentiality for those who request as such.**

សិក្ខាសាលានេះ បានទទួល ថវិកាឧបត្ថម្ភ ពី អង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (DED) ។

This seminar is fully funded by the German Development Service (DED).